# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ....០៥..សសរ..

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការដឹកនាំ និងដំណើរការ លំហាត់ហ្វឹកហ្វឺនប្រតិបត្តិការសន្តិភាពពហុសាសន៍ ឆ្នាំ ២០១០

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២ / នស/ ៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចលេខ ១៣ សសរ ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការកែសម្រួលគណៈកម្មាធិការសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំង ចូលរួមបេសកកម្មថែរក្សាសន្តិភាព របស់អង្គការសហប្រជាជាតិ
- បានឃើញសេចក្តីសម្រេចលេខ ១៨ សសរ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីអំពីរបៀបរបបការងារ និងការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំរាជរដ្ឋាភិបាល
- យោងតាមសំណូមពរចាំបាច់របស់គណៈកម្មាធិការសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ

## សម្រេច

**ប្រការ ១ :** ត្រូវបានបង្កើតគណៈកម្មការដឹកនាំ និងដំណើរការលំហាត់ហ្វឹកហ្វឺនប្រតិបត្តិការ សន្តិភាពពហុសាសន៍ ឆ្នាំ ២០១០ ជាភាសាអង់គ្លេស(GPOI PKO CAPSTONE 2010) ហៅកាត់ថាគណៈកម្មការ GPOI-10 ស្ថិតក្រោមការគ្រប់គ្រងចង្អុលណែនាំផ្ទាល់ពីឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**ប្រការ ២ :** សមាសភាពគណៈកម្មការ GPOI-10 មានឈ្មោះ ដូចខាងក្រោម :

១- ឯកឧត្តម ប្រាក់ សុខុន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជារដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី    ប្រធាន

www.pheakdeylaw.com

២- ឯកឧត្តម អ៊ុក រ៉ាប៊ុន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជារដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អនុប្រធាន

៣-ឯកឧត្តម នាយឧត្តមសេនីយ៍ ម៉ឹង សំផន រដ្ឋលេខាធិការក្រសួងការពារជាតិ អនុប្រធាន

៤- ឯកឧត្តម ហាក់ សាវុធ រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៥- ឯកឧត្តម ម៉ៅ ហាវណ្ណាល់ រដ្ឋលេខាធិការ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សមាជិក

៦- ឯកឧត្តម កង ហ៊ាង អភិបាលខេត្តកំពង់ស្ពឺ សមាជិក

៧- ឯកឧត្តម នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ សមាជិក

៨- ឯកឧត្តម ស ចេង អគ្គនាយករង នៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សមាជិក

៩- ឯកឧត្តម ឧត្តមសេនីយ៍ឯក សំ វណ្ណថន អគ្គលេខាធិការក្រសួងការពារជាតិ សមាជិក

១០-ឯកឧត្តម ឧត្តមសេនីយ៍ឯក ចៅ ភីរុណ អគ្គនាយកអគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស ក្រសួងការពារជាតិ សមាជិក

១១-ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ុំ សំណាង អគ្គនាយកអគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ ក្រសួងការពារជាតិ សមាជិក

១២-ឯកឧត្តម ឧត្តមសេនីយ៍ឯក មាស សារិន អគ្គនាយកអគ្គនាយកដ្ឋានយោធសេវា ក្រសួងការពារជាតិ សមាជិក

១៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក ណឹម សុវត្ថិ អគ្គនាយក អគ្គនាយកដ្ឋាននយោបាយ និងកិច្ចការបរទេស ក្រសួងការពារជាតិ សមាជិកប្រចាំការ

១៤-ឯកឧត្តម ឧត្តមសេនីយ៍ឯក សែម សុវណ្ណនី ប្រធានមជ្ឈមណ្ឌលបោសសំអាតមីន យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនិងបណ្តុះបណ្តាល សមាជិកប្រចាំការ

១៥-ឯកឧត្តម ឧត្តមសេនីយ៍ឯក ធូ ស៊ុន នាយកខុទ្ទកាល័យ អគ្គបញ្ជាការ សមាជិក

១៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក សៅ សុខា មេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក

១៧-ឯកឧត្តម ឧត្តមសេនីយ៍ឯក ស៊ឹង សំណាង មេបញ្ជាការកងទ័ពជើងអាកាស សមាជិក

១៨-ឯកឧត្តម ឧត្តមសេនីយ៍ឯក ជា សារិន មេបញ្ជាការរងនិងជានាយសេនាធិការកងទ័ពជើងគោក សមាជិក

១៩- ឯកឧត្តម ឧត្តមសេនីយ៍ឯក ឥត សារ៉ាត់ នាយកទីចាត់ការហ្វឹកហ្វឺន អគ្គបញ្ជាការ សមាជិក

២០-ឯកឧត្តម ឧត្តមសេនីយ៍ឯក មាស សំអុល នាយកនាយកដ្ឋានបុគ្គលិក ក្រសួងការពារជាតិ សមាជិក

២១- ឯកឧត្តម ឧត្តមសេនីយ៍ទោ ឡាញ់ កៅ មេបញ្ជាការបញ្ជាការដ្ឋានរថក្រោះ អគ្គបញ្ជាការ សមាជិក ។

**ប្រការ ៣** : គណៈកម្មការ GPOI-10 អាចបន្ថែមសមាជិកមួយចំនួនទៀតតាមការចាំបាច់ ។

**ប្រការ ៤** : គណៈកម្មការ GPOI-10 នេះ មានមុខងារ និងភារកិច្ច ដូចតទៅ :

-កំណត់ឈ្មោះរបស់លំហាត់ហ្វឹកហ្វឺន

-កំណត់ប្រទេសដែលត្រូវចូលរួម

-កំណត់ទីកន្លែងសម្រាប់ធ្វើលំហាត់ហ្វឹកហ្វឺននៅទីលាន (FTX)

-កំណត់ទីកន្លែងសម្រាប់ធ្វើលំហាត់ហ្វឹកហ្វឺនទីបញ្ជាការ (CPX)

-សម្រេចអំពីសំណង់ដែលត្រូវកសាងដោយភាគីអាមេរិកសម្រាប់ FTX

-ជ្រើសរើស និងពិនិត្យលើដំណើរការសាងសង់ហេដ្ឋារចនាសម្ព័ន្ធហ្វឹកហ្វឺនសម្រាប់ FTX

-តាក់តែង និងសម្របសម្រួលសេណារីយ៉ូ (Scenario) សម្រាប់ CPX

-រៀបចំផែនការអំពីដំណើរការរបស់ CPX

-កំណត់សមាសភាពគ្រប់ជាន់ថ្នាក់ដែលត្រូវចូលរួមទាំង FTX និង CPX

www.pheakdeylaw.com

-ជ្រើសរើសមេបញ្ជាការកងកម្លាំង (Force Commander) សម្រាប់ CPX

-កំណត់អ្នកគ្រប់គ្រងលំហាត់ CPX

-សម្របសម្រួលការស្នាក់នៅ ហូបចុករបស់អ្នកចូលរួម (FTX, CPX, Observers, VIP Guests)

-គិតគូរអំពីកម្លាំងរក្សាសន្តិសុខសម្រាប់ FTX និង CPX

-គិតគូរអំពីមធ្យោបាយដឹកជញ្ជូនដែលត្រូវធានា

-រៀបចំមន្ទីរពេទ្យចល័ត និងមធ្យោបាយសង្គ្រោះ ដែលអាចទុកចិត្តបាន សម្រាប់ FTX និង CPX

-អនុវត្តភារកិច្ចផ្សេងៗទៀតដែលឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ ប្រគល់ជូន ។

**ប្រការ ៥ :** គណៈកម្មការ GPOI-10 នេះមានអនុគណៈកម្មការមួយចំនួនជាសេនាធិការ ។ ការបង្កើតអនុគណៈកម្មការមួយចំនួននេះ និងការតែងតាំងសមាសភាពនៃអនុគណៈកម្មការនីមួយៗ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ តាមសំណើរបស់គណៈកម្មការ GPOI-10 ។

**ប្រការ ៦ :** ថវិកាចំណាយរបស់គណៈកម្មការ GPOI-10 នេះ ស្ថិតក្នុងកញ្ចប់ថវិកាពិសេសរបស់រាជរដ្ឋាភិបាល ។

**ប្រការ ៧ :** សមាជិកទាំងអស់របស់គណៈកម្មការ GPOI-10 នេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ គណៈកម្មការនេះអាចប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីសម្រួលការងារ ។

**ប្រការ ៨ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងស្ថាប័នដែលពាក់ព័ន្ធ អគ្គបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គស្នងការនគរបាលជាតិ ប្រធាន អនុប្រធាន និងសមាជិក ដែលមានរាយនាមក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែមករា ឆ្នាំ ២០០៩

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៨
- ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com